គណបក្ស សិទ្ធិមនុស្ស

HUMAN RIGHTS PARTY

បំរើ ការពារ កសាង

កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ

*ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍* *ថ្ងៃសុក្រ ទី៦ ខែមីនា ឆ្នាំ២០០៩* *ព្រឹត្តិប័ត្រលេខ០៧៥ ឆ្នាំទី២*


| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -ក្រសួងការបរទេសសហរដ្ឋអាមេរិក បង្ហាញរបាយការណ៍ពីស្ថានភាព សិទ្ធិមនុស្សនៅកម្ពុជា | ១ |
| -បើទោះជាការបោះឆ្នោតត្រូវបានបញ្ចប់តែការរើសអើងផ្នែកនយោបាយ នៅតែបន្ត | ១ |
| -ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សចុះសួរសុខទុក្ខសកម្មជននៅខេត្តកំពង់ចាម | ២ |
| -រណសិរ្សលោកតាសឹងសានរៀបចំពិធីរំលឹកខួបលើកទី៣០ | ៣ |


## ក្រសួងការបរទេសសហរដ្ឋអាមេរិក បង្ហាញរបាយការណ៍ពីស្ថានភាព សិទ្ធិមនុស្សនៅកម្ពុជា

លោក **រ៉ុង ឈុន** ប្រធានសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជាបានលើកឡើងថា របាយកាណ៏របស់ក្រសួងការបទេសសហរដ្ឋអាមេរិកដែលបានលើកឡើង គឺឆ្លុះបញ្ចាំងនូវស្ថានភាពពិតទាក់ទងនឹងស្ថេរភាពគោរពសិទ្ធិមនុស្ស ដែលមិនត្រូវបានអនុវត្តដោយរដ្ឋាភិបាលកម្ពុជា ។ ឯប្រព័ន្ធតុលាការវិញនៅតែមាននិន្នាការនយោបាយមិនស្ថិតនៅឯករាជ្យ មានអំពើពុករលួយ និងការរំលោភបំពានទៅលើសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងការបំបិទសិទ្ធិធ្វើកូដកម្ម បាតុកម្មដែលក្នុងនោះអាជ្ញាធរបានប្រើអំពើហឹង្សាផងដែរ ។ លោកបន្ថែមទៀតថា នៅពេលដែលសហគមន៏អន្តរជាតិលើករបាយការណ៏រិះគន់ស្តីពីប្រទេសកម្ពុជា រដ្ឋាភិបាលតែងតែធ្វើការប្រមាថ និងខ្វះការយកចិត្តទុកដាក់ចំពោះរបាយការណ៏ទាំងនោះទេ ។

លោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យរបស់គណបក្សសិទ្ធិមនុស្សមានប្រសាសន៏ថា ប្រទេសកម្ពុជាយើងច្បាប់ស្ថិតនៅក្នុងសៀវភៅ ច្បាប់នៅនឹងមាត់អ្នកមានអំណាច ហើយលោកក៏បានគាំទ្ររបាយការណ៏របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកផងដែរ ។ ដោយក្នុងនោះលោកបានបង្ហាញអំពីអំពើពុករលួយក្នុងប្រព័ន្ធតុលាការក្រោមហេតុផលថា សព្វថ្ងៃនេះគេប្រើតុលាការតាមរបៀបរបបកុំម្មុយនីស្ត ។ តុលាការមិនឯករាជ្យស្ថិតក្រោមឥទ្ធិពលអ្នកមានអំណាច ។ លោកបានបន្ថែមទៀតថាការរំលោភសិទ្ធិមនុស្សពាក់ព័ន្ធនឹងដីធ្លីកាន់តែធ្ងន់ឡើងៗ ពាសពេញផ្ទៃប្រទេសតួយ៉ាងនៅតំបន់ភូមិភាគឥសាន មានការរំលោភបំពានសម្បត្តិធម្មជាតិ កេរដំណែលជនជាតិភាគតិចជាដើម និងនៅជនបទមានការរំលោភបំពានយកដីធ្លី និងបឹងបួរជាដើម ។

## បើទោះជាការបោះឆ្នោតត្រូវបានបញ្ចប់ តែការរើសអើងផ្នែកនយោបាយនៅតែបន្ត

រហូតមកដល់ពេលនេះ ការបោះឆ្នោតថ្នាក់ជាតិបានបញ្ចប់ប្រមាណ៨ខែហើយ ប៉ុន្តែអាជ្ញាធរមូលដ្ឋាននៅស្រុកកំពង់លែងខេត្តកំពង់ឆ្នាំងនៅតែរើសអើងគណបក្សនយោបាយ ។ ជាមួយគ្នានេះសកម្មជនគណបក្សសិទ្ធិមនុស្សនៅឃុំដា ក្នុងស្រុកកំពង់លែង

ថ្លែងថា មេភូមិប្រាសាទ ឃុំដាមានការរើសអើងប្រជាពលរដ្ឋ ហើយនៅពេលពួកគាត់ទៅពឹងពាក់ ឱ្យអាជ្ញាធរភូមិឃុំស៊ីញ៉េលើលិខិតស្នាមអ្វីមួយ ឬសុំច្បាប់បុណ្យទាននោះ អាជ្ញាធរទាំងនោះសំដែងឥរិយាបថព្រងើយកន្តើយ និងបោះពាក្យសំដីដល់ប្រជាពលរដ្ឋណាដែលពួកគេយល់ថា មិនមែនជាសមាជិក សមាជិកាគណបក្សប្រជាជនកម្ពុជា ។ សកម្មជនរូបនោះបានបន្តទៀតថា ប្រការដែលអាជ្ញាធរភូមិរើសអើងប្រកាន់បួកក្រអើតក្រទម ដាក់ប្រជារាស្ត្ររបស់ខ្លួនយ៉ាងដូច្នេះវាធ្វើឱ្យប្រជាពលរដ្ឋកាន់តែបែងចែកបក្សនេះបក្សនោះ ហើយការរាក់ទាក់រាប់អានគ្នាទៅវិញទៅមកកាន់តែឃ្លាតឆ្ងាយពីគ្នា ។

សកម្មជនថ្នាក់ស្រុកកំពង់លែង គណបក្សសិទ្ធិមនុស្សបានបញ្ជាក់ថា នៅស្រុកកំពង់លែងមាន៩ឃុំ និង៤៩ភូមិអាជ្ញាធរភូមិឃុំ និងសមត្ថកិច្ចប៉ូលីសក៏មានការរើសអើងផងទៀត ។ នៅពេលប្រជាពលរដ្ឋទៅពឹងពាក់អាជ្ញាធរជាពិសេសការខ្ចីលុយពីធនាគារ រឺអង្គការផ្សេងៗ គឺពួកគាត់តែងតែសុំភាគរយ និងមិនព្រមធ្វើការធានាជូនដល់ពួកទាំងនោះទេ ។

ប្រធានក្រុមការងារខេត្តកំពង់ឆ្នាំង គណបក្សសិទ្ធិមនុស្សថ្លែងថា ការប្រកាន់រើសអើងគណបក្សនយោបាយនៅតែមាន គឺមានច្រើននៅក្នុងខេត្តកំពង់ឆ្នាំង ។ ជាឧទាហរណ៏នៅឃុំស្រែខ្មៅនៅពេលលោកជួបបណ្តាញ ឬសកម្មជនគណបក្សសិទ្ធិមនុស្សនៅភូមិត្រពាំងស្បូវ គឺមេភូមិលបលួចយកការណ៏ថែមទៀតផង ។

លោក **សំ ច័ន្ទគា** អ្នកសំរបសំរួលនៃសមាគមអាដហុកដែលាមានទីតាំងនៅខេត្តកំពង់ឆ្នាំងបានបញ្ជាក់ថា ប្រសិនបើអាជ្ញាធរមូលដ្ឋាននៅតែប្រកាន់និន្នាការនយោបាយរើសអើង គឺធ្វើបានឱ្យប្រជាពលរដ្ឋបែកបាក់គ្នា ។ យើងដឹងហើយថា ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាក៏បានបង្ហាញអំពីការបែកបាក់ ប្រេះស្រាំគ្នារួចទៅហើយ ដូច្នេះអាជ្ញាធរគួរតែលុបបំបាត់ចោលនូវវប្បធម៌ទាំងនេះ ។

យើងមិនអាចសុំការស្រាយបំភ្លឺពីលោក **មាន់ អាន់លី** អភិបាលស្រុកកំពង់លែងបានទេ ជុំវិញពីបញ្ហានៃការរើសអើងនេះដោយលោកប្រាប់ថា កំពុងរវល់រៀនសូត្រ ។

សូមជម្រាបថា ការរើសអើង និងការលាបពណ៌ពលរដ្ឋពីសំណាក់អាជ្ញាធរមូលដ្ឋាន គឺមាននៅគ្រប់ទីកន្លែងនៅក្នុងប្រទេសក្រោមការដឹកនាំរបស់គណបក្សកាន់អំណាច ។

## ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សចុះសួរសុខទុក្ខសកម្មជននៅខេត្តកំពង់ចាម

នៅថ្ងៃទី២ ខែមីនានេះ ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់លោក **កឹម សុខា** ប្រធានគណបក្សជួបសំណេះសំណាល និងការសួរសុខទុក្ខសកម្មជន អ្នកគាំទ្រគណបក្សសិទ្ធិមនុស្សនៅឃុំរកាគ៥ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

បើតាមការលើកឡើងរបស់លោក **ណុប ថេត** លេខាធិការគណបក្សសិទ្ធិមនុស្សប្រចាំខេត្តកំពង់ចាមឱ្យដឹងថា ពិធីសំណេះសំណាលនេះប្រារព្ធធ្វើនៅភូមិត្រពាំងថ្លា ឃុំរកាគ៥ ស្រុកត្បូងឃ្មុំ ហើយមានសកម្មជន និងប្រជាពលរដ្ឋចូលរួមស្តាប់ប្រសាសន៏លើកឡើងរបស់ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ជាច្រើនប្រកបដោយទឹកមុខស្រស់ស្រាយសប្បាយចិត្ត ដោយសារពួកគាត់ចង់ជួបថ្នាក់ដឹកនាំរបស់គណបក្សសិទ្ធិមនុស្ស ។ លោកបន្តទៀតថា អ្នកចូលរួមគឺសុទ្ធតែចង់ឱ្យប្រទេសជាតិមានអ្នកដឹកនាំ ដើរតាមគោលការប្រជាធិបតេយ្យ និងចង់ឱ្យប្រជាពលរដ្ឋរស់នៅមានជីវភាពធូរធារដូចបណ្តាប្រទេសនានា រីឯអ្នកដឹកនាំប្រទេសសព្វថ្ងៃមិនទាន់ដើរចំទិសដៅលិទ្ធិប្រជាធិបតេយ្យ ។ ទាក់ទងនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានលោក **ណុប ថេត** បានបញ្ជាក់ថា កសិផលរបស់កសិករដូចជា ពោត សណ្តែក ដំឡូង រដ្ឋាភិបាលមិនជួយរកទីផ្សារជូនពួកគាត់ ហើយធ្វើឱ្យពួកគាត់ខ្វះទុនបង្វិល និងត្រូវខាតបង់គ្មានប្រាក់ចំណេញ ។

លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្សបានមានប្រសាសន៏ទៅកាន់ប្រជាពលរដ្ឋផ្តោតទៅលើ ស្ថានភាពនយោបាយក្រោយពេលបោះឆ្នោត ដែលលោកបានបញ្ជាក់ថា គណបក្សប្រជាជនគ្រប់គ្រងប្រទេសទាំងស្រុង ពោលគឺទាំងក្នុងរដ្ឋសភា និងរដ្ឋាភិបាលដែលការណ៏នេះអាចមានគ្រោះថ្នាក់ដល់ប្រទេសជាតិ និងគោលការណ៏លទ្ធិប្រជាធិបតេយ្យ ពីព្រោះគណបក្សប្រជាជនអនុវត្តតាមរបៀបកុំម្មុយនីស្ត ហើយឫសគល់នៃគណបក្សប្រជាជន មានប្រភពមកពី

គណបក្សកុំម្មុយនីស្តឥណ្ឌូចិនរបស់ហូជីមិញ ដែលជាអ្នកដឹកនាំរបស់យួន ។ លោកបានបន្តទៀតថា សេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន ដែលចំណូលថវិកាជាតិពឹងផ្អែកលើវិស័យកាត់ដេរ វិស័យទេសចរណ៍ ប៉ុន្តែដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក ធ្វើឱ្យវិស័យទាំងពីរនេះជួបបញ្ហា ។ ចំណុចដែលសំខាន់នោះគឺកសិកម្ម តែបើកសិករគ្មានដើមទុន និងទីផ្សារសំរាប់លក់ផលិតផលនោះធ្វើឱ្យជីវភាពរបស់ពួកគាត់នឹងជួបការលំបាក មិនតែដីធ្លីរបស់ពួកគាត់កំពុងតែបាត់បង់បន្តិចម្តងៗ ដោយរដ្ឋាភិបាលប្រមូលដីទាំងនោះ ឱ្យពួកវិនិយោគបរទេសរាប់សិបម៉ឺនហិកតា ។ លោកបានបន្តទៀតថា បញ្ហាដើមទុនប្រជាពលរដ្ឋ គឺមិនមានដើមទុនសំរាប់ផលិត ហើយកសិករទាំងនោះបានទៅខ្ចីពីធនាគារដោយការប្រាក់ខ្ពស់ ។ ដែលនេះជាបញ្ហាមួយដែលរដ្ឋាភិបាលបច្ចុប្បន្នត្រូវតែគិតគូរពិចារណាឡើងវិញ ។

## រណសិរ្សលោកតាសឺនសានរៀបចំ ពិធីរំលឹកខួបលើកទី៣០

នៅព្រឹកថ្ងៃទី៥ ខែមីនានេះ ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ដែលមានលោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស លោក **សឺន ស៊ូប៊ែរ្តិ៍** ប្រធានគណៈកម្មាធិការនាយក និងលោក **កៀត សុគន្ធ** អនុប្រធានគណបក្សសិទ្ធិមនុស្ស បានចូលរួមក្នុងពិធីបុណ្យរំឭកខួបលើកទី៣០នៃចលនារណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ ដែលប្រារព្ធធ្វើនៅភូមិស្រែអំពិល ឃុំឈើទាល ស្រុកគៀនស្វាយ ខេត្តកណ្តាល ។

លោក **សឺន ស៊ូប៊ែរ្តិ៍** ប្រធានគណៈកម្មាធិការនាយករបស់គណបក្សសិទ្ធិមនុស្សបានមានប្រសាសន៍ថា ពិធីនេះប្រារព្ធធ្វើឡើងដើម្បីសម្ពោធសិលាចរឹកស្តូប ដែលចារឈ្មោះអ្នកដែលតស៊ូ ក្នុងជួររណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។ ក្នុងរណសិរ្សនោះមានផ្នែកកងទ័ពមានលោកឧត្តមសេនីយ៍ **ឌៀវ ដែន** ចំណែកខាងរណសិរ្សជាតិមានសម្តេចបវរសេដ្ឋាធិបតី **សឺន សាន** ជាប្រធាន និងជានាយករដ្ឋមន្ត្រីក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្តេចព្រះបាទនរោត្តមសីហនុ។ លោកបានបន្តទៀតថា រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរគឺមានភាគីរដ្ឋាភិបាលចំរុះ ដែលអង្គការសហប្រជាជាតិទទួលស្គាល់ហើយ ប្រសិនបើអត់មានរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ក៏ទ័ពបរទេសយួនមិនចាកចេញពីប្រទេសយើងដែរ ។

រីឯលោក **កៀត សុគន្ធ** អនុប្រធានគណបក្សសិទ្ធិមនុស្ស ដែលមានវត្តមាននៅក្នុងពិធីនោះបានមានប្រសាសន៍ថា អ្នកដែលបូជាជីវិតដើម្បីបុព្វហេតុជាតិនាភូមិស្រែអំពិល ឃុំឈើទាល ស្រុកកៀនស្វាយត្រូវបានរៀបចំជាសិលាចារឹកដើម្បីបូជា និងការគោរពដល់បងប្អូនយុទ្ធជន យុទ្ធនារីក៏ដូចជាបងប្អូនប្រជាពលរដ្ឋខ្មែរ ដែលធ្លាប់ចូលរួមចលនាតស៊ូក្នុងការរំដោះប្រទេសជាតិ ចេញពីបរទេសឈ្លានពានក្នុងកំឡុងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩១ ។

សូមរំឭកថា ចលនារណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ដែលមានទីតាំងស្ថិតនៅជាប់ជាយដែនខ្មែរសៀម បានកើតឡើងថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៧៩ ហើយរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរនេះមានការទទួលស្គាល់ពីអង្គការសហប្រជាជាតិផងដែរបន្ទាប់មកមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស២៣តុលា១៩៩១ ដែលមានប្រទេស១៨ជាម្ចាស់ហត្ថលេខី ទើបប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជាផ្លូវការ និងប្រវត្តិសាស្ត្រក្រោមកិច្ចរៀបចំរបស់អង្គការសហប្រជាជាតិនៅថ្ងៃទី២៧កក្កដា១៩៩៣ ។

## សេចក្តីជូនដំណឹង

អគ្គលេខាធិការដ្ឋានគណបក្សសិទ្ធិមនុស្ស មានកិត្តិយសជម្រាបជូនដំណឹងចំពោះសមាជិក សមាជិកា និងគណៈកម្មាធិការប្រតិបត្តិគ្រប់លំដាប់ថ្នាក់នៅទូទាំងប្រទេសឱ្យបានជ្រាបថា កន្លងមកសមាជិករបស់គណបក្សសិទ្ធិមនុស្ស មួយចំនួនមានជាអាទិ៍ លោក កែវ រ៉េមី , កឹម សុខុន , ចាន់ វ៉ីន , លឹម រតនៈ , រាជ សំរេច , ទូច និលគីរី , រ័ត្ន បូរី , ផាន់ សឿន , ចាន់ ចេន , ឡុង មិនណាប់ , សួន សារ៉ាន់ , ថៃ រដ្ឋ ។ល។ បានរត់ទៅសុំចុះចូលជាមួយគណបក្សកាន់អំណាចដើម្បីលាភៈសក្ការៈ និងផលប្រយោជន៍ផ្ទាល់ខ្លួន ។ ក្នុងចំណោមជនទាំងអស់នេះមានមួយចំនួនបានយកតួនាទីរបស់ខ្លួនកាលនៅក្នុងគណបក្សទៅទាក់ទងបោកប្រាស់ សមាជិក សមាជិកា របស់គណបក្សសិទ្ធិមនុស្ស ប្រយោជន៍ទាក់ទាញសមាជិក សមាជិកា យើងឱ្យចូលបំរើប្រយោជន៍ គណបក្សដែលពួកគេបានចុះចូល និងដើម្បីប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ ។

ន័យដូចបានជម្រាបជូនខាងលើ អគ្គលេខាធិការដ្ឋានសូមបញ្ជាក់ថា ពួកអ្នកទាំងអស់ខាងលើនេះ ត្រូវបានបាត់បង់តួនាទី និងសមាជិកភាពរបស់ខ្លួនពីគណបក្ស ដោយស្វ័យប្រវត្តិចាប់តាំងពីថ្ងៃដែលពួកគេបានរត់ទៅចុះចូលម្លេះហើយ ពួកគេពុំមានសិទ្ធិអ្វីនៅក្នុងគណបក្សសិទ្ធិមនុស្សទៀតឡើយ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសមាជិក សមាជិកាទាំងអស់ជ្រាប និងកុំចាញ់ឧបាយកលជនទាំងនោះតទៅទៀត និងជួយធ្វើការផ្សព្វផ្សាយជូនដល់សមាជិក សមាជិកានៅតាមមូលដ្ឋានរបស់ឱ្យបានជ្រាប ។

ភ្នំពេញ ថ្ងៃ០៥ ខែមីនា ឆ្នាំ២០០៩

ព័ត៌មានបន្ថែមសូមទំនាក់ទំនង
ទូរស័ព្ទលេខ ០១៧ ៣០៣ ៩០០

## កម្មវិធីវគ្គបណ្តុះបណ្តាលសំរាប់យុវជន
## គណបក្សសិទ្ធិមនុស្ស
## មុខវិជ្ជាសិក្សា
## ជំនាញនៃការទំនាក់ទំនង

Communication Skills

**កម្មវិធីរួមមាន**

- យុទ្ធសាស្ត្រនៃការទំនាក់ទំនង
  Communication Strategy
- ពិធីការ
  Protocol

កម្មវិធីនេះសិក្សានៅរៀងរាល់ថ្ងៃអង្គារ៍ រយៈពេលពីរសប្តាហ៍ សិក្សា៥ម៉ោងកន្លះ/ថ្ងៃ ។ ពេលបញ្ចប់វគ្គមានចេញលិខិតបញ្ជាក់ការសិក្សាជូនដោយឥតគិតថ្លៃជូនដល់សិក្ខាកាមផងដែរ ។ កម្មវិធីនេះមានបន្ថែមទៅលើកម្មវិធីសិក្សាជារៀងរាល់ថ្ងៃសុក្រ ដែលមានដូចជា ជំនាញភាពជាអ្នកដឹកនាំ , រដ្ឋបាល និងវិទ្យាសាស្ត្រនយោបាយ ។


| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| លោក | ម៉ី សាន | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| កញ្ញា | គង់ វណ្ណា | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |


**ការអប់រំ និងបណ្តុះបណ្តាលយុវជនជាបញ្ហាចំបងដែលត្រូវដោះស្រាយ!**